**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៣៩ **អយក.**សណន

# សេចក្តីណែនាំ
# ស្តីពី
# ការទប់ស្កាត់ការធ្វើសកម្មភាពឬឃោសនានយោបាយ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈនិងគ្រឹះស្ថានសិក្សាឯកជន

កន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានសង្កេតឃើញថា នៅតាមគ្រឹះស្ថានសិក្សាទាំងសាធារណៈ ទាំងឯកជន មានសមាគម អង្គការ បុគ្គលិកអប់រំ និងគ្រូបង្រៀនជាប់កិច្ចសន្យាមួយចំនួន បានធ្វើសកម្មភាពមិនប្រក្រតី ដោយបានធ្វើការផ្សព្វផ្សាយ បោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំរបស់សមាគម អង្គការទាំងនោះ និងឃោសនាបំផុសគំនិតឱ្យបុគ្គលិកអប់រំចូលរួមសកម្មភាពជាមួយ។ សមាគម អង្គការខ្លះបានបង្កើតឱ្យមានជាសាខានៅតាមគ្រឹះស្ថានសិក្សាទាំងសាធារណៈ ទាំងឯកជន ព្រមទាំងធ្វើសកម្មភាពជ្រៀតជ្រែកការងារគ្រប់គ្រងអប់រំថែមទៀតផង។ សកម្មភាពទាំងនេះ បានធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ក្នុងគ្រឹះស្ថានសិក្សា ដែលផ្ទុយនឹងគោលការណ៍អព្យាក្រឹត្យភាពរបស់គ្រឹះស្ថានសិក្សា ជាពិសេសផ្ទុយពីច្បាប់ស្តីពីការអប់រំ។

ដើម្បីទប់ស្កាត់រាល់សកម្មភាពមិនប្រក្រតី និងការធ្វើសកម្មភាពឬឃោសនានយោបាយនៅតាមគ្រឹះស្ថានសិក្សាទាំងសាធារណៈ ទាំងឯកជនឱ្យមានប្រសិទ្ធភាព និងឱ្យស្របតាមច្បាប់ស្តីពីការអប់រំ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោម៖

១. មិនអនុញ្ញាតឱ្យសមាគម អង្គការ ឬភ្នាក់ងារណាមួយ ធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានសិក្សាដោយគ្មានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡាឡើយ។

២. មិនអនុញ្ញាតឱ្យធ្វើសកម្មភាពនយោបាយនិង/ឬការឃោសនានយោបាយឱ្យគណបក្សនយោបាយណាមួយនៅក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ឬស្ថាប័នអប់រំឡើយ ស្របតាមមាត្រា៣៤នៃច្បាប់ស្តីពីការអប់រំ។

៣. ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬក្រសួងអប់រំ យុវជន និងកីឡាស្របតាមមាត្រា៤២នៃច្បាប់ស្តីពីការអប់រំ ក្នុងការស្នើសុំទីតាំងគ្រឹះស្ថានសិក្សាសាធារណៈ និងការផ្សព្វផ្សាយព័ត៌មានអប់រំគ្រប់រូបភាពណាក៏ដោយ នៅក្នុងបរិវេណគ្រឹះស្ថានសិក្សាសាធារណៈ។

៤. ក្នុងករណីបុគ្គលិកអប់រំធ្វើសកម្មភាពឱ្យប៉ះពាល់ដល់អព្យាក្រឹតភាពរបស់ស្ថាប័នអប់រំ និងគ្រឹះស្ថានសិក្សា ត្រូវទទួលទណ្ឌកម្ម តាមមាត្រា ៥២ នៃច្បាប់ស្តីពីការអប់រំដែលកំណត់ថា៖

- គ្រប់សកម្មភាពនយោបាយ ឬការឃោសនានយោបាយ ឱ្យគណបក្សនយោបាយណាមួយនៅក្នុងស្ថាប័នអប់រំ ឬគ្រឹះស្ថានសិក្សាដែលផ្ទុយនឹងមាត្រា ៣៤ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន)រៀល។
- ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ។
- ចំពោះនីតិបុគ្គលត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន)រៀល។
- ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ។
- បើអំពើដូចបានកំណត់នៅក្នុងវាក្យខណ្ឌទី១ ខាងលើ ប្រព្រឹត្តដោយនីតិបុគ្គលដែលជាស្ថាប័នអប់រំ ឬគ្រឹះស្ថានសិក្សា ហើយស្ថិតក្នុងករណីមិនរាងចាល ត្រូវព្យួរជាបណ្តោះអាសន្ន ឬដកហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំរបស់ស្ថាប័អប់រំ ឬ គ្រឹះស្ថានសិក្សានោះ។

ទទួលបានសេចក្តីណែនាំនេះ ប្រធានអង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ប្រធានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ សាកលវិទ្យាធិការ នាយកគ្រឹះស្ថានសិក្សាទាំងសាធារណៈ ទាំងឯកជន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់បុគ្គលិកអប់រំគ្រប់ឋានានុក្រមឱ្យអនុវត្តតាមសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងយុត្តិធម៌
  "ដើម្បីជូនជ្រាប
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡា
  "ដើម្បីសហការ និងអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា. នីតិកម្ម